ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ:.....២១៤.......កប/ប្រ.ក

ក្រសួងពត៌មាន
មកដល់ថ្ងៃទី 05-11-08
ម៉ោង 8.00'
លេខ 1539 ពម

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៨

# ប្រកាស
## ស្តីពី
## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០០៩

**រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យ លេខ ១៤៣ អនក្រ/បក. ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០០៩

## ស ម្រេ ច

**ប្រការ១.-** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅ ឆ្នាំ២០០៩ ដោយត្រូវអនុញ្ញាតឱ្យកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារ ដោយមានប្រាក់ឈ្នួលតាម ការកំណត់ដូចតទៅ:

-បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ មករា

-បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា

-បុណ្យមាឃបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ កុម្ភៈ

-បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ មីនា ជំនួសថ្ងៃទី ០៨ ខែ មីនា ដែលចំថ្ងៃអាទិត្យ

-បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី ១៤ - ១៥ និងថ្ងៃទី ១៦ ខែ មេសា

-បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ ឧសភា

-បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ ឧសភា

-ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ១២ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនបីថ្ងៃ គឺថ្ងៃទី១៣ - ១៤ និងថ្ងៃទី ១៥ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រីព្រះវររាជមាតា **នរោត្តម មុនិនាថ សីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ១៨ ខែ មិថុនា

-បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ១៨ - ១៩ និងថ្ងៃទី ២១ ខែ កញ្ញា ជំនួសថ្ងៃទី ២០ ខែ កញ្ញា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញចំនួនមួយថ្ងៃ គឺថ្ងៃទី ២៤ ខែ កញ្ញា

-ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនមួយថ្ងៃ គឺថ្ងៃទី ២៩ ខែ តុលា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះវររាជបិតា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣១ ខែ តុលា

-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ចំនួនបីថ្ងៃ គឺថ្ងៃទី ០២ - ០៣ និងថ្ងៃទី០៤ ខែ វិច្ឆិកា ជំនួសថ្ងៃទី ០១ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ

-បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ វិច្ឆិកា

-បុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិ ចំនួនមួយថ្ងៃ គឺថ្ងៃទី ១០ ខែ ធ្នូ ។

**ប្រការ២.-** ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា ១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យ សម្រាប់កម្មករនិយោជិតទាំងអស់ ។

**ប្រការ៣.-** ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ២០៦ កប/ប្រ.ក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**វង សូត**

**<u>ចម្លងជូន</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចតេជោ ហ៊ុន សែន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សហព័ន្ធសហជីព កម្មករនិយោជិត
  "ដើម្បីជ្រាប និងអនុវត្ត"
- កាលប្បវត្តិ និងឯកសារ